PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

# បណ្ណសន្យារ៉ាប់រងនៃកិច្ចសន្យាធានារ៉ាប់រង
# PRUសុវត្ថិភាពខ្ញុំ

នៅក្នុងឯកសារស្តីពី ខ និងលក្ខខណ្ឌនេះ ពាក្យថា “**អ្នក**” ឬ “**របស់អ្នក**” សំដៅដល់ម្ចាស់បណ្ណសន្យារ៉ាប់រង។ ពាក្យថា “**យើងខ្ញុំ**” “**របស់យើងខ្ញុំ**” “**ក្រុមហ៊ុនព្រូដិនសលកម្ពុជា**” ឬ “**ក្រុមហ៊ុន**” សំដៅដល់ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឺសួរិនស៍ ម.ក ។

## ១. និយមន័យ

**១.១. ម្ចាស់បណ្ណសន្យារ៉ាប់រង** សំដៅដល់ នីតិបុគ្គលដែលបានចុះបញ្ជី និងប្រតិបត្តិការក្នុងប្រទេសកម្ពុជា ឬ ជារូបវន្តបុគ្គលដែល មានសញ្ជាតិខ្មែរ ឬដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាយ៉ាងហោចណាស់រយៈពេល ៦ ខែ ដោយមានអាសយដ្ឋានពិតប្រាកដនៅប្រទេសកម្ពុជា មានអាយុចាប់ពី ដប់ប្រាំបី (១៨) ឆ្នាំឡើងទៅ មានសមត្ថភាពពេញលេញក្នុងការធ្វើសកម្មភាពរដ្ឋប្បវេណី និងជាអ្នកដែលបំពេញ និងយល់ព្រមលើទម្រង់បែបបទពាក្យស្នើសុំធានារ៉ាប់រង និងជាអ្នកបង់បុព្វលាភធានារ៉ាប់រង។

**១.២. អ្នកត្រូវបានធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គលទាំងឡាយណាដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា នៅពេលជាវបណ្ណសន្យារ៉ាប់រង ដែលត្រូវបានតែងតាំងដោយម្ចាស់បណ្ណសន្យារ៉ាប់រង ហើយក៏ជាអ្នកដែលត្រូវបានធានារ៉ាប់រងដោយបណ្ណសន្យារ៉ាប់រង និងត្រូវបានទទួលយកដោយក្រុមហ៊ុន សម្រាប់ការធានារ៉ាប់រងក្រោម ខ និងលក្ខខណ្ឌដូចមានកំណត់នៅក្នុងឯកសារនេះ។

**១.៣. អ្នកទទួលផល** គឺជារូបវន្តបុគ្គលដែលបានកំណត់ដោយម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងការទទួលអត្ថប្រយោជន៍មរណភាពនិងត្រូវបានទទួលយកដោយក្រុមហ៊ុន សម្រាប់ការធានារ៉ាប់រងក្រោម ខ និងលក្ខខណ្ឌដែលមានចែងនៅក្នុងឯកសារនេះ។

**១.៤. អត្ថគាហក/អត្ថគាហកចុងក្រោយ** សំដៅដល់រូបវន្តបុគ្គល ដែលត្រូវបានចាត់តាំងដោយម្ចាស់បណ្ណសន្យារ៉ាប់រង ដើម្បីកាន់កាប់ ឬត្រួតត្រាចុងក្រោយបង្អស់ទៅលើក្រុមហ៊ុន នៅពេលដែលម្ចាស់បណ្ណសន្យារ៉ាបរងគឺជាក្រុមហ៊ុន។ អត្ថគាហកត្រូវបានកំណត់ថាជាបុគ្គលដែលកាន់កាប់ ឬគ្រប់គ្រងចុងក្រោយបង្អស់ ដោយផ្ទាល់ ឬប្រយោលលើក្រុមហ៊ុន ដោយការកាន់កាប់ភាគហ៊ុនឬសិទ្ធិបោះឆ្នោត ឬក៏ជាបុគ្គលកាន់កាប់តាមរយៈមធ្យោបាយផ្សេងៗ នៅពេលដែលមិនមានបុគ្គលមានសិទ្ធិជាម្ចាស់កម្មសិទ្ធិណាម្នាក់ ឬពុំអាចកំណត់បុគ្គលដែលកំពុងកាន់កាប់សិទ្ធិជាអត្ថគាហកចុងក្រោយបាន។ នៅពេលពុំអាចកំណត់ថាបុគ្គលណាមួយជាអត្ថគាហកចុងក្រោយរបស់ក្រុមហ៊ុន បុគ្គលដែលកាន់កាប់មុខតំណែងជាមន្ត្រីគ្រប់គ្រងជាន់ខ្ពស់នៅក្នុងក្រុមហ៊ុនរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង នឹងត្រូវបានចាត់ទុកជាអត្ថគាហកចុងក្រោយ។

**១.៥. បុព្វលាភធានារ៉ាប់រង** គឺជាចំនួនទឹកប្រាក់ដែលម្ចាស់បណ្ណសន្យារ៉ាប់រងនឹងត្រូវបង់ទៅឲ្យក្រុមហ៊ុនដោយសាមីខ្លួនផ្ទាល់ ឬ ដោយភាគីទីបី តាមរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង និងអត្ថប្រយោជន៍ដូចដែលបានជ្រើសរើស។ ម្ចាស់បណ្ណសន្យារ៉ាប់រងមានកាតព្វកិច្ចបង់ពន្ធនានាលើបណ្ណសន្យារ៉ាប់រងដែលបានចេញនោះ ដោយយោងទៅតាមបទប្បញ្ញត្តិជាធរមាន។ បុព្វលាភធានារ៉ាប់រងអាចនឹងផ្លាស់ប្តូររៀងរាល់ពេលបន្តបណ្ណសន្យារ៉ាប់រង ហើយបុព្វលាភធានារ៉ាប់រងនឹងមិនត្រូវបានបង្វិលសងវិញនោះទេ នៅពេលមានការលុបចោល ឬបញ្ចប់បណ្ណសន្យារ៉ាប់រង។

**១.៦. រយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង** គឺជារយៈពេលមួយដែលការធានារ៉ាប់រងអាយុជីវិតត្រូវបានផ្តល់ឲ្យ។

**១.៧. បណ្ណសន្យារ៉ាប់រង** សំដៅទៅលើឯកសារចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ដែលចេញដោយក្រុមហ៊ុន ដោយមានកំណត់ពី ខ្លឹមសារសំខាន់ៗ និងខ ដោយចែងពីលក្ខខណ្ឌលម្អិតដែលបានព្រមព្រៀងរវាងក្រុមហ៊ុន និងម្ចាស់បណ្ណសន្យារ៉ាប់រង។ ម្ចាស់បណ្ណសន្យារ៉ាប់រងជារូបវន្តបុគ្គលត្រូវបានអនុញ្ញាតឲ្យទិញគម្រោងមូលដ្ឋាននេះសម្រាប់សាមីខ្លួនផ្ទាល់ និងអនីតិជន (អាយុក្រោម ១៨ ឆ្នាំ)ប៉ុណ្ណោះ។ បើមិនដូច្នេះទេ បណ្ណសន្យារ៉ាប់រងនឹងក្លាយជាមោឃៈ។

**១.៨. កាលបរិច្ឆេទចាប់ផ្តើមសុពលភាពការធានារ៉ាប់រង** ការធានារ៉ាប់រងនឹងចាប់ផ្តើមមានសុពលភាពនៅថ្ងៃបន្ទាប់នៃថ្ងៃចេញបណ្ណសន្យារ៉ាប់រង លើកលែងតែមានចែងផ្សេងពីនេះ នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត ឬនៅក្នុងទម្រង់បញ្ជាក់ដែលមានភាពសមមូល។

**១.៩. “គ្រោះថ្នាក់ចៃដន្យ”** សំដៅលើហេតុការណ៍ដែលមិនអាចដឹងមុន និងដោយអចេតនាដែលជាមូលហេតុផ្ទាល់

បណ្ដាលឲ្យ ហេតុការណ៍ត្រូវបានធានាកើតឡើង តាមមធ្យោបាយហិង្សា និងកត្តាសត្យានុម័តផ្សេងៗ ហើយដែលមិន បណ្ដាលមកពីមូលហេតុ ដូចជា ជំងឺ ឬរោគារបស់អ្នកត្រូវបានធានារ៉ាប់រង។ ករណីធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យ មានរបួសស្នាមលើខ្លួនឯង ដែលប្រព្រឹត្តដោយអ្នកត្រូវបានធានារ៉ាប់រង ទោះបីជាស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ នៅក្នុងអំឡុងពេលណាមួយដែលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាព នឹងមិនត្រូវបានចាត់ទុកថាជា គ្រោះថ្នាក់ចៃដន្យឡើយ។

១.១០. “**គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ**” សំដៅលើឧបទ្ទវហេតុ ឬគ្រោះថ្នាក់ចៃដន្យ ដែលកើតឡើងតាមដងផ្លូវ ដែលបើកឲ្យចរាចរជាសាធារណៈ ក្នុងអំឡុងពេលបណ្ណសន្យារ៉ាប់រងមានសុពលភាព ដែលបង្កឲ្យមានការស្លាប់ ឬរបួសលើបុគ្គលម្នាក់ ឬច្រើននាក់។ គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវនេះត្រូវបង្កឡើងយ៉ាងហោចណាស់ដោយយានជំនិះដែលមានចលនាមួយ ហើយត្រូវរួមបញ្ចូលការប៉ះទង្គិចរវាងយានជំនិះ និងយានជំនិះ រវាងយានជំនិះ និង បុគ្គល និងរវាងយានជំនិះ និងសត្វពាហនៈ ឬវត្ថុណាមួយដែលជាឧបសគ្គ។

១.១១. “**គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយម៉ូតូ ម៉ូតូសណ្ដោងរ៉ឺម៉ក ម៉ូតូកង់បី ឬ ម៉ូតូកង់បួន**” សំដៅលើឧបទ្ទវហេតុ ឬគ្រោះថ្នាក់ ចៃដន្យដែលកើតឡើងតាមដងផ្លូវដោយម៉ូតូ ម៉ូតូសណ្ដោងរ៉ឺម៉ក ម៉ូតូកង់បី ឬម៉ូតូកង់បួន ដោយអ្នកត្រូវបានធានារ៉ាប់រង ត្រូវ តែជាអ្នកបើកបរ ឬជាអ្នកដំណើរនៃម៉ូតូ ម៉ូតូសណ្ដោងរ៉ឺម៉ក ម៉ូតូកង់បី ឬម៉ូតូកង់បួននោះផ្ទាល់។ ប្រការនេះ នឹងត្រូវ ពិចារណា រួម គ្នាជាមួយនឹងប្រការ “**គ្រោះថ្នាក់ចៃដន្យ**” និង “**គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ**”។

១.១២. “**គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយរថយន្តគ្រួសារ រថយន្តទេសចរណ៍ ឬរថយន្តក្រុង**” សំដៅលើឧបទ្ទវហេតុ ឬ គ្រោះថ្នាក់ចៃដន្យដែលកើតឡើងតាមដងផ្លូវដោយរថយន្តគ្រួសារ រថយន្តទេសចរណ៍ ឬរថយន្តក្រុង ដោយអ្នកត្រូវ បាន ធានារ៉ាប់រងត្រូវតែជាអ្នកបើកបរ ឬជាអ្នកដំណើរនៃរថយន្តគ្រួសារ រថយន្តទេសចរណ៍ ឬរថយន្តក្រុងនោះផ្ទាល់។ ប្រការនេះ នឹងត្រូវពិចារណារួមគ្នាជាមួយនឹងប្រការ “**គ្រោះថ្នាក់ចៃដន្យ**” និង “**គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ**”។

១.១៣. “**ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**” គឺជាស្ថានភាពមួយដែលអសមត្ថភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ហើយ មាន ទម្រង់ដូចខាងក្រោម៖

- ការបាត់បង់ទាំងស្រុង ឬការមើលមិនឃើញ និងមិនអាចជាសះស្បើយជារៀងរហូតនៃភ្នែកទាំងពីរ **ឬ**
- ការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងរហូតនៃមុខងារប្រើប្រាស់របស់ ដៃ/ជើងទាំងពីរ នៅត្រង់កដៃ/កជើង ឬចាប់ពីផ្នែកខាងលើនៃ កដៃ/កជើង **ឬ**
- ការបាត់បង់ទាំងស្រុង ឬការមើលមិនឃើញ និងមិនអាចជាសះស្បើយជារៀងរហូតនៃភ្នែកម្ខាង និងការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងរហូតនៃមុខងារប្រើប្រាស់របស់ដៃ/ជើងម្ខាង នៅត្រង់កដៃ/កជើង ឬចាប់ពីផ្នែកខាងលើនៃកដៃ/កជើង។

នៅក្នុងករណីដែលមានការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងរហូតនៃមុខងារប្រើប្រាស់នៃដៃ ឬជើងម្ខាង ឬទាំងពីរ នៅត្រឹមកដៃ/កជើង ឬចាប់ពីផ្នែកខាងលើនៃកដៃ/កជើង ការវិភាគកោសល្យវិច្ច័យពីអាការៈនេះត្រូវធ្វើឡើងដោយមន្ទីរពេទ្យដែលមានចុះបញ្ជីត្រឹមត្រូវនៅថ្នាក់ខេត្ត ឬរាជធានី ដោយមិនឲ្យតិចជាងរយៈពេលប្រាំមួយ (៦)ខែ ហើយក៏មិនឲ្យលើសពីរយៈពេលប្រាំបួន (៩)ខែ គិតចាប់តាំងពីថ្ងៃដែលមានហេតុការណ៍ត្រូវបានធានាកើតឡើង ឬក៏គិតចាប់ពីថ្ងៃដែលការវិភាគកោសល្យវិច្ច័យអំពី អាការៈនេះត្រូវបានបញ្ជាក់ត្រឹមត្រូវដោយយកកាលបរិច្ឆេទចុងក្រោយ។

នៅក្នុងករណីដែលមានការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងរហូត ការវិភាគកោសល្យវិច្ច័យអំពីអាការៈនេះអាចធ្វើឡើងនៅពេលណាមួយក៏បាន នៅតាមមន្ទីរពេទ្យដែលមានចុះបញ្ជីត្រឹមត្រូវ នៅថ្នាក់ខេត្ត ឬរាជធានី។ ការវិភាគកោសល្យវិច្ច័យពីអាការៈនេះ អាចធ្វើឡើងនៅពេលណាមួយក៏បាននៅក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង និងនៅក្នុងរយៈពេលដែលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាពនៅឡើយ។

១.១៤. “**មន្ទីរពេទ្យ**” សំដៅលើគ្រឹះស្ថានរដ្ឋ ឬឯកជនស្របច្បាប់ដែលបានចុះបញ្ជី និងត្រូវបានទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

- ប្រតិបត្តិការជាចម្បងសម្រាប់ការទទួលថែទាំ និងព្យាបាលជំងឺចំពោះអ្នកឈឺ និងរងរបួសដែលសម្រាកនៅមន្ទីរពេទ្យ

- ផ្តល់ជូនសេវាថែទាំ ២៤ ម៉ោងក្នុងមួយថ្ងៃ ដោយគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីត្រឹមត្រូវ
- មានបុគ្គលិកដែលជាគ្រូពេទ្យយ៉ាងតិចមួយនាក់ដែលប្រចាំការ
- មានគ្រឿងបរិក្ខារគ្រប់គ្រាន់ត្រឹមត្រូវ ដើម្បីធ្វើការវិភាគកោសល្យវិច្ឆ័យ និងការវះកាត់ធំៗ
- មិនមែនជាគ្លីនិក មណ្ឌលថែទាំ ឬគ្រឹះស្ថានប្រហាក់ប្រហែល ឬមណ្ឌលថែទាំចាស់ជរា អ្នកដែលមានបញ្ហាផ្លូវចិត្ត អ្នកញៀនស្រា ឬគ្រឿងញៀន និង
- មានបំពាក់ឧបករណ៍សម្រាប់ ការថតកាំរស្មីអ៊ិច (X-Ray) និងគ្រឿងបរិក្ខារសម្រាប់វះកាត់ជាដើម។

**២. លក្ខខណ្ឌទាក់ទងនឹងបណ្ណសន្យារ៉ាប់រងរបស់អ្នក**

សម្រាប់ការចេញបណ្ណសន្យារ៉ាប់រងនៃផលិតផលនេះ អ្នកត្រូវបានធានារ៉ាប់រងនឹងមិនតម្រូវឲ្យមានធ្វើការពិនិត្យសុខភាពឡើយ។ លក្ខខណ្ឌផ្សេងៗទាក់ទងនឹងផលិតផលនេះត្រូវបានរៀបរាប់ដូចខាងក្រោម៖

**២.១. អត្ថប្រយោជន៍**

អត្ថប្រយោជន៍ករណីគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ នឹងអាស្រ័យទៅលើប្រភេទអត្ថប្រយោជន៍ធានារ៉ាប់រងដែលបានជ្រើសរើស ដែលក្នុងនោះមាន (1). គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយម៉ូតូ ម៉ូតូសណ្តោងរ៉ឺម៉ក ម៉ូតូកង់បី ឬ ម៉ូតូកង់បួន; (2). គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយរថយន្តគ្រួសារ រថយន្តទេសចរណ៍ ឬរថយន្តក្រុង និង (3). គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវទូទៅ។

ប្រសិនបើគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយម៉ូតូ ម៉ូតូសណ្តោងរ៉ឺម៉ក ម៉ូតូកង់បី ឬ ម៉ូតូកង់បួនត្រូវបានជ្រើសរើស នោះអត្ថប្រយោជន៍ដូចរៀបរាប់ខាងក្រោម (ចំណុច ក) នឹងត្រូវបានទូទាត់ នៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដែលមានពាក់ព័ន្ធនឹងអ្នកត្រូវបានធានារ៉ាប់រង ដែលជាអ្នកបើកបរ ឬជាអ្នកដំណើរនៃម៉ូតូ ម៉ូតូសណ្តោងរ៉ឺម៉ក ម៉ូតូកង់បី ឬ ម៉ូតូកង់បួននោះផ្ទាល់។

ប្រសិនបើគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយរថយន្តគ្រួសារ រថយន្តទេសចរណ៍ ឬរថយន្តក្រុង ត្រូវបានជ្រើសរើស នោះអត្ថប្រយោជន៍ដូចរៀបរាប់ខាងក្រោម (ចំណុច ក)  នឹងត្រូវបានទូទាត់ នៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ ដែលមានពាក់ព័ន្ធនឹងអ្នកត្រូវបានធានារ៉ាប់រង ដែលជាអ្នកបើកបរ ឬ ជាអ្នកដំណើរនៃរថយន្តគ្រួសារ រថយន្តទេសចរណ៍ ឬរថយន្តក្រុងនោះផ្ទាល់។

ប្រសិនបើគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវទូទៅ ត្រូវបានជ្រើសរើស នោះអត្ថប្រយោជន៍ដូចរៀបរាប់ខាងក្រោម នឹងត្រូវបានទូទាត់នៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ។

ក. **អត្ថប្រយោជន៍ករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍៖** ១០០% នៃអត្ថប្រយោជន៍ករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ នឹងត្រូវផ្តល់ជូន ក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រងបានទទួលមរណភាពបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយផ្ទាល់ ហើយមរណភាពកើតឡើងក្នុងអំឡុងពេល ១៨០ថ្ងៃ រាប់ពីថ្ងៃដែលហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍បានកើតឡើង។

អត្ថប្រយោជន៍ខាងលើនឹងត្រូវបានទូទាត់តែម្តងប៉ុណ្ណោះក្នុងអំឡុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង ចំពោះអ្នកត្រូវបានធានារ៉ាប់រងម្នាក់។ បណ្ណសន្យារ៉ាប់រងនឹងត្រូវបញ្ចប់បន្ទាប់ពីការទូទាត់ខាងលើ ហើយពុំមានអត្ថប្រយោជន៍នឹងត្រូវទូទាត់បន្តទៀតទេ។

**២.២. ករណីមិនធានា**

ក្រុមហ៊ុននឹងបដិសេធក្នុងការទូទាត់អត្ថប្រយោជន៍ដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើការទាមទារសំណងរបស់អ្នកត្រូវបានធានារ៉ាប់រងត្រូវបានកើតឡើងដូចលក្ខខណ្ឌខាងក្រោម៖

ក. ការធ្វើអត្តឃាត ឬ ការប៉ុនប៉ងធ្វើអត្តឃាត ឬ ធ្វើឲ្យរបួសខ្លួនឯង ឬ ការដែលមិនបានប្រើប្រាស់សមត្ថភាពឲ្យសមហេតុផលដើម្បីជៀសវាងពីការរងរបួស ទោះបីជាអ្នកត្រូវបានធានារ៉ាប់រង ស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬ មិនប្រក្រតីក៏ដោយ។
ខ. ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីបទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្ត ដោយអ្នកទទួលផលម្នាក់ ឬច្រើននាក់ អ្នកត្រូវបានធានារ៉ាប់រង ម្ចាស់បណ្ណសន្យារ៉ាប់រង និង អត្តគាហក នោះមានតែអ្នកទទួលផល អ្នកត្រូវបានធានារ៉ាប់រង ម្ចាស់បណ្ណសន្យារ៉ាប់រង ឬ អត្តគាហក ដែលមិនពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌប៉ុណ្ណោះ ដែលនៅមានសិទ្ធិក្នុងការទទួលអត្ថប្រយោជន៍។
គ. ការប្រើគ្រឿងញៀន ឬថ្នាំសប្បាយ ការទទួលរងគ្រោះដោយការគេចវេស ឬទប់ទល់នឹងការចាប់ខ្លួនរបស់មន្ត្រីអនុវត្តច្បាប់ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬ/និង ការបើកបរហួសល្បឿនកំណត់ ឬ ការបើកបរយានជំនិះនៅអាយុដែលមិនបានអនុញ្ញាតដោយច្បាប់ ឬ មិនមានបណ្ណបើកបរត្រឹមត្រូវ ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន
ឃ. ការចូលរួមនៅក្នុងសកម្មភាពប្រណាំងបើកបរ
ង. មានជំងឺផ្លូវចិត្ត ជំងឺថប់បារម្ភ ឬជំងឺប្រព័ន្ធសរសៃប្រសាទ
ច. បញ្ហារាងកាយដែលមានស្រាប់មុនពេលកាលបរិច្ឆេទចាប់ផ្ដើមសុពលភាពការធានារ៉ាប់រង

## ២.៣. ការទាមទារសំណង

ការទាមទារសំណងលើហេតុការណ៍ដែលត្រូវបានធានា ត្រូវតែធ្វើឡើង និងត្រូវដាក់សំណើសុំមកកាន់ក្រុមហ៊ុនក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីការកើតឡើងនៃឧបទ្ទវហេតុ។ ក្រុមហ៊ុននឹងទូទាត់ប្រាក់អត្ថប្រយោជន៍ស្របតាម ខ និងលក្ខខណ្ឌនេះ លុះត្រាណាតែក្រុមហ៊ុនទទួលបានភស្តុតាងដែលចាំបាច់ និងអាចទុកចិត្តបានសម្រាប់ការទូទាត់សំណង។ ឯកសារខាងក្រោមនេះ ចាំបាច់ត្រូវមានសម្រាប់ការវាយតម្លៃទៅលើការទាមទារសំណង៖

ក. ទម្រង់បែបបទទាមទារសំណង
ខ. របាយការណ៍ប៉ូលីសទាក់ទងនឹងគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ
គ. របាយការណ៍វេជ្ជសាស្ត្រ រួមបញ្ចូលទាំង របាយការណ៍ពិនិត្យជាតិអាកុល ឬសារធាតុញៀន ដើម្បី សន្មតថាគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវមិនបណ្ដាលមកពីការបើកបរដោយមានជាតិស្រវឹង ឬគ្រឿងញៀន
ឃ. ភស្តុតាងពីកាសែត ឬទស្សនាវដ្ដី ដែលបង្ហាញពីហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ (ប្រសិនបើមាន)។

បន្ថែមលើឯកសារខាងលើ ឯកសារផ្សេងទៀតដែលចាំបាច់ត្រូវមានសម្រាប់ការវាយតម្លៃទៅលើការទាមទារសំណងមានដូចជា៖

ក. **ករណីមរណភាព៖** ការទាមទារសំណងត្រូវមានភ្ជាប់មកជាមួយ
- សំបុត្រមរណភាព
- សំបុត្រមរណភាពក្រៅប្រទេស ឬលិខិតនៃការដឹកសពចូលមកក្នុងប្រទេសកំណើតវិញ ឬ លិខិតបូជាសព ប្រសិនបើហេតុការណ៍មរណភាពកើតឡើងនៅក្រៅប្រទេសកម្ពុជា

ខ. **ករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍៖** ការទាមទារសំណងត្រូវភ្ជាប់មកជាមួយនឹងលិខិតបញ្ជាក់ពីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដោយគ្រូពេទ្យជំនាញពីគ្លីនិក ឬមន្ទីរពេទ្យដែលមានចុះបញ្ជី។

## ២.៤. អ្នកទទួលផល

ក. អ្នកមានសិទ្ធិទទួលផលលំដាប់ដំបូង គឺម្ចាស់បណ្ណសន្យារ៉ាប់រង ទោះបីជាអ្នកទទួលផលដែលត្រូវបានចាត់តាំង គឺជា

អ្នកដទៃផ្សេងពីម្ចាស់បណ្ណសន្យារ៉ាប់រងក៏ដោយ លើកលែងតែអត្ថប្រយោជន៍ករណីមរណភាព។

- ❖ សម្រាប់ករណីមរណភាព ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង គឺជាមនុស្សតែម្នាក់ ហើយម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសអត្ថប្រយោជន៍ករណីមរណភាព នោះអ្នកទទួលផលត្រូវតែតែងតាំង។ អ្នកទទួលផលបានកំណត់ជាស្វ័យប្រវត្តិតាម ខនិងលក្ខខណ្ឌនេះ ប៉ុន្តែម្ចាស់បណ្ណសន្យារ៉ាប់រងក៏មានសិទ្ធិក្នុងការកែប្រែ អ្នកទទួលផលម្នាក់ ឬច្រើននាក់ភ្លាមៗ ក្រោយពេលបណ្ណសន្យារ៉ាប់រងបានចេញដោយក្រុមហ៊ុន។ ប្រសិនបើមិនមានអ្នកទទួលផលដែលផ្លាស់ប្តូរ ឬតែងតាំងសារជាថ្មីដោយម្ចាស់បណ្ណសន្យារ៉ាប់រងនោះទេ នោះការទូទាត់ប្រាក់អត្ថប្រយោជន៍ធានារ៉ាប់រង នឹងត្រូវផ្តល់ជូនអ្នកទទួលផលម្នាក់ ឬច្រើននាក់ដែលបានកំណត់ដោយស្វ័យប្រវត្តិ យោងតាមលំដាប់ដូចមានកំណត់ខាងក្រោម៖

- ៥០% នៃប្រាក់សំណងអត្ថប្រយោជន៍នឹងត្រូវបានផ្តល់ជូនទៅសហព័ទ្ធស្របច្បាប់
- ៥០% នៃប្រាក់សំណងអត្ថប្រយោជន៍នឹងត្រូវបានផ្តល់ជូនទៅកាន់លំដាប់ភាគីដូចខាងក្រោម

  ទី១. ប្តីប្រពន្ធស្របច្បាប់ និងកូន(ៗ) ស្មើៗគ្នា

  ទី២. ប្តីប្រពន្ធស្របច្បាប់ និងឪពុក-ម្តាយ ស្មើៗគ្នា

  ទី៣. ប្តីប្រពន្ធស្របច្បាប់ និងបងប្អូនបង្កើត ស្មើៗគ្នា

  ទី៤. បុគ្គលផ្សេងទៀតដែលសម្រេចដោយតុលាការ។

ខ. ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង គឺជាមនុស្សផ្សេងគ្នា នោះម្ចាស់បណ្ណសន្យារ៉ាប់រង គឺជាអ្នកត្រូវទទួលបានអត្ថប្រយោជន៍ ដោយមិនចាំបាច់មានការតែងតាំងអ្នកទទួលផលសម្រាប់អត្ថប្រយោជន៍ធានារ៉ាប់រងនេះឡើយ។

ឃ. អ្នកអាចផ្លាស់ប្តូរអ្នកទទួលផលនៅក្នុងកម្មវិធី Pulse (Pulse App) ក្នុងអំឡុងពេលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាព។

ង. ការមិនអាចផ្តល់ឯកសារបញ្ជាក់ពីទំនាក់ទំនងផ្លូវច្បាប់រវាងអ្នកទទួលផល-អ្នកត្រូវបានធានារ៉ាប់រង និង/ឬម្ចាស់បណ្ណសន្យារ៉ាប់រង-អ្នកត្រូវបានធានារ៉ាប់រង អាចបណ្តាលឲ្យមានការបដិសេធក្នុងពេលទូទាត់សំណង។

ច. ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះភាពស្របច្បាប់នៃការតែងតាំងអ្នកទទួលផលម្នាក់ ឬច្រើននោះឡើយ។

## ២.៥. ការបញ្ចប់បណ្ណសន្យារ៉ាប់រង

បណ្ណសន្យារ៉ាប់រងនេះត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ នៅពេលដែលហេតុការណ៍ណាមួយខាងក្រោមកើតឡើង៖

ក. មរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រងនៅក្រោមបណ្ណសន្យារ៉ាប់រង ឬ

ខ. បន្ទាប់ពីទទួលបានសំណើរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងការបោះបង់បណ្ណសន្យារ៉ាប់រង ឬ

គ. ដល់ថ្ងៃផុតកំណត់នៃរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង ឬ

ឃ. អ្នកត្រូវបានធានារ៉ាប់រងរហូតដល់អាយុចិតសិប (៧០) ឆ្នាំ (អាយុថ្ងៃខួបកំណើតចុងក្រោយ) ឬ

ង. ក្រុមហ៊ុនបញ្ចប់គម្រោងមូលដ្ឋានស្របតាម ខ និងលក្ខខណ្ឌដែលមានចែងក្នុងនេះ ឬ

ច. មានស្ថានភាពផ្សេងទៀតដែលកំណត់ដោយច្បាប់ស្តីពីការធានារ៉ាប់រងដែលមានស្រាប់។

## ២.៦. ការផ្តល់ព័ត៌មានមិនពិតអំពីព័ត៌មានសំខាន់ៗ

អ្នក និងអ្នកត្រូវបានធានារ៉ាប់រងក្រោមបណ្ណសន្យារ៉ាប់រងនេះ មានកាតព្វកិច្ចផ្តល់នូវរាល់ព័ត៌មានទាំងឡាយណា ដែលមានសារៈសំខាន់សម្រាប់ធ្វើការវាយតម្លៃហានិភ័យ ដើម្បីចេញបណ្ណសន្យារ៉ាប់រង និងការធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះ។

ប្រសិនបើព័ត៌មានណាមួយដែលបានផ្តល់ឲ្យយើងខ្ញុំពុំមានភាពត្រឹមត្រូវ យើងខ្ញុំរក្សាសិទ្ធិក្នុងការបញ្ចប់បណ្ណសន្យារ៉ាប់រង ឬបដិសេធលើការស្នើសុំទាមទារសំណង។ ក្នុងករណីបណ្ណសន្យារ៉ាប់រងត្រូវបានបញ្ចប់ នោះបុព្វលាភធានារ៉ាប់រងដែលបានបង់រួចនឹងមិនត្រូវបានទូទាត់ជូនវិញឡើយ។

## ២.៧. ការដោះស្រាយវិវាទ

ចំពោះគ្រប់វិវាទដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ។

ចំពោះវិវាទដែលមិនអាចដោះស្រាយតាមរយៈការផ្សះផ្សាខាងលើ ភាគីនីមួយៗអាចដាក់វិវាទនេះទៅដោះស្រាយនៅតុលាការនៃអាសយដ្ឋានដែលទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុនតាំងនៅ។ ថ្លៃចំណាយផ្សេងៗលើតុលាការជាបន្ទុករបស់ភាគីចាញ់ក្តី។ រយៈពេលកំណត់សម្រាប់ការដាក់បណ្តឹង ត្រូវមានអំឡុងពេលប្រាំ (៥) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍ដែលនាំឲ្យកើតមានវិវាទដោយយោងទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធក្នុងប្រទេសដែលមានជាធរមាន។

## ២.៨. ប្រការស្តីពី ទណ្ឌកម្ម

"ទណ្ឌកម្ម" មានន័យថា វិធានការរឹតត្បិតដែលបានដាក់លើ របបនយោបាយ ប្រទេស រដ្ឋាភិបាល អង្គភាព បុគ្គល និងឧស្សាហកម្មទាំងឡាយណា ដែលបានកំណត់ដោយស្ថាប័នអន្តរជាតិ ឬរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា ឬនៅក្រៅប្រទេសកម្ពុជា ដែលរាប់បញ្ចូលដូចជា ការិយាល័យអនុវត្តទណ្ឌកម្មហិរញ្ញវត្ថុនៃរតនាគារជាតិរបស់ចក្រភពអង់គ្លេស អង្គការសហប្រជាជាតិ សហភាពអឺរ៉ុប ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិបរទេសនៃនាយកដ្ឋានរតនាគារសហរដ្ឋអាមេរិក និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

ផ្ទុយពីព័ត៌មានដែលបានផ្តល់នៅក្នុងបណ្ណសន្យារ៉ាប់រងនេះ ប្រសិនបើ

(i) យើងដឹង ឬទទួលបានដំណឹងថាម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអត្ថគាហកដទៃទៀត ដែលមានឈ្មោះក្នុងដំណាក់កាលដាក់ពាក្យស្នើសុំ អ្នកត្រូវបានចាត់តាំងអ្នកទទួលផល បុគ្គលណាម្នាក់ ឬអង្គភាពទាំងឡាយណាដែលមានទំនាក់ទំនងជាមួយបណ្ណសន្យារ៉ាប់រងនេះ (រាប់បញ្ចូលទាំងអ្នកបង់ប្រាក់) មានឈ្មោះក្នុងបញ្ជីទណ្ឌកម្មណាមួយឬ

(ii) ប្រសិនបើយើង ឬធនាគារ ឬភាគីទីបីដែលពាក់ព័ន្ធត្រូវបានរកឃើញថាមានការរំលោភបំពានទៅលើកាតព្វកិច្ចនៃគោលការណ៍ដាក់ទណ្ឌកម្ម តាមរយៈការចាត់វិធានការណាមួយទៅលើបណ្ណសន្យារ៉ាប់រងនេះ វាចាំបាច់ដែល សុពលភាពរបស់បណ្ណសន្យារ៉ាប់រងនេះត្រូវបានបញ្ចប់ភ្លាមៗ និង/ឬការចាត់វិធានការផ្សេងទៀតដែលយើងគិតថាសមរម្យដូចជា ការជូនដំណឹងដល់អាជ្ញាធរ រដ្ឋាភិបាលដែលពាក់ព័ន្ធ នឹងការឃាត់ឃាំងការទូទាត់ប្រាក់ ការបង្កក់ប្រាក់ណាមួយដែលបានទូទាត់ជូនយើងខ្ញុំ និងការផ្ទេរ ឬទូទាត់សាច់ប្រាក់ ទៅកាន់អាជ្ញាធរ រដ្ឋាភិបាលដែលពាក់ព័ន្ធណាមួយ។

យើងក៏នឹងមិនទទួលខុសត្រូវចំពោះរាល់ការខាតបង់ណាមួយដែលអ្នក ឬនរណាម្នាក់ផ្សេងទៀតអាចនឹងទទួលរង ដោយសារការចាត់វិធានការរបស់យើងចំពោះប្រការខាងលើនោះទេ។

ប្រការនេះ និងលទ្ធភាពរបស់យើងក្នុងការទាមទារសម្រាប់ការខាតបង់ណាមួយ ដែលកើតមានឡើងដោយប្រការណាមួយខាងលើនឹងនៅតែមានសុពលភាពដដែល ទោះបីជាបណ្ណសន្យារ៉ាប់រងនេះត្រូវបានបញ្ចប់ក៏ដោយ។

PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

# ខ និងលក្ខខណ្ឌ
# ផលិតផលធានារ៉ាប់រងបន្ថែម អត្ថប្រយោជន៍គ្រោះថ្នាក់លើដងផ្លូវ

ខ និងលក្ខខណ្ឌនៃធានារ៉ាប់រងបន្ថែមនេះ រួមមានកិច្ចព្រមព្រៀងបន្ថែមរវាងក្រុមហ៊ុនព្រូដិនសលកម្ពុជា និងម្ចាស់បណ្ណសន្យារ៉ាប់រង ដើម្បីផ្តល់ការធានារ៉ាប់រងដល់អ្នកត្រូវបានធានារ៉ាប់រង ដែលមានសិទ្ធិស្របច្បាប់ក្នុងការទទួលបានប្រយោជន៍ពីការធានារ៉ាប់រងចំពោះម្ចាស់បណ្ណសន្យារ៉ាប់រង។

ពាក្យដែលត្រូវបានប្រើនៅក្នុងផលិតផលធានារ៉ាប់រងបន្ថែមនេះ ត្រូវមានន័យដូចគ្នាដូចនៅក្នុង ខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រងដែលបានចុះហត្ថលេខា (ដែលជាគម្រោងមូលដ្ឋាន ដែលធានារ៉ាប់រងបន្ថែមនេះត្រូវបានភ្ជាប់មកជាមួយ)។ ក្នុងករណីមានភាពខុសគ្នារវាងលក្ខខណ្ឌបន្ថែមនេះ និងបណ្ណសន្យារ៉ាប់រងដែលបានចុះហត្ថលេខា នោះបញ្ញត្តិ នៅក្នុងធានារ៉ាប់រងបន្ថែមនេះត្រូវយកជាគោល។

**១. និយមន័យ**

**១.១. បណ្ណសន្យារ៉ាប់រង** សំដៅទៅលើឯកសារចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ដែលចេញដោយក្រុមហ៊ុន ដោយមានកំណត់ពីខ្លឹម សារសំខាន់ៗ និងខ ដោយចែងពីលក្ខខណ្ឌលម្អិតដែលបានព្រមព្រៀងរវាងក្រុមហ៊ុន និងម្ចាស់បណ្ណសន្យារ៉ាប់រង។ ម្ចាស់បណ្ណសន្យារ៉ាប់រងជារូបវន្តបុគ្គលត្រូវបានអនុញ្ញាតឲ្យទិញគម្រោងមូលដ្ឋាននេះសម្រាប់សាមីខ្លួនផ្ទាល់ និងអនីតិជន (អាយុក្រោម ១៨ ឆ្នាំ) ប៉ុណ្ណោះ។ បើមិនដូច្នេះទេបណ្ណសន្យារ៉ាប់រងនឹងក្លាយជាមោឃៈ។

**១.២. បុព្វលាភធានារ៉ាប់រង** គឺជាចំនួនទឹកប្រាក់ដែលម្ចាស់បណ្ណសន្យារ៉ាប់រងនឹងត្រូវបង់ទៅឲ្យក្រុមហ៊ុនដោយសាមីខ្លួនផ្ទាល់ ឬ ដោយភាគីទីបី តាមរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង និងអត្ថប្រយោជន៍ដូចដែលបានជ្រើសរើស។ ម្ចាស់បណ្ណសន្យារ៉ាប់រងមានកាតព្វកិច្ចបង់ពន្ធនានាលើបណ្ណសន្យារ៉ាប់រងដែលបានចេញនោះ ដោយយោងទៅតាមបទប្បញ្ញត្តិជាធរមាន។ បុព្វលាភធានារ៉ាប់រងអាចនឹងផ្លាស់ប្តូររៀងរាល់ពេលបន្តបណ្ណសន្យារ៉ាប់រង ហើយបុព្វលាភធានារ៉ាប់រងនឹងមិនត្រូវបានបង្វិលសងវិញនោះទេ នៅពេលមានការលុបចោល ឬបញ្ចប់បណ្ណសន្យារ៉ាប់រង។

**១.៣. កាលបរិច្ឆេទចាប់ផ្តើមសុពលភាពការធានារ៉ាប់រង** ការធានារ៉ាប់រងនឹងចាប់ផ្តើមមានសុពលភាពនៅថ្ងៃបន្ទាប់នៃថ្ងៃចេញបណ្ណសន្យារ៉ាប់រង លើកលែងតែមានចែងផ្សេងពីនេះ នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត ឬនៅក្នុងទម្រង់បញ្ជាក់ដែលមានភាពសមមូល។

**១.៤. "គ្រោះថ្នាក់ចៃដន្យ"** សំដៅលើហេតុការណ៍ដែលមិនអាចដឹងមុន និងដោយអចេតនាដែលជាមូលហេតុផ្ទាល់បណ្តាលឲ្យ ហេតុការណ៍ត្រូវបានធានាកើតឡើង តាមមធ្យោបាយហិង្សា និងកត្តាសត្យានុម័តផ្សេងៗ ហើយដែលមិនបណ្តាលមក ពីមូលហេតុដូចជា ជំងឺ ឬរោគារបស់អ្នកត្រូវបានធានារ៉ាប់រង។ ករណីធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យមានរបួសស្នាមលើខ្លួនឯងដែលប្រព្រឹត្តដោយអ្នកត្រូវបានធានារ៉ាប់រង ទោះបីជាស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ នៅក្នុងអំឡុងពេលណាមួយដែលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាព នឹងមិនត្រូវបានចាត់ទុកថាជាគ្រោះថ្នាក់ចៃដន្យឡើយ។

**១.៥. "គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ"** សំដៅលើឧបទ្ទវហេតុ ឬគ្រោះថ្នាក់ចៃដន្យ ដែលកើតឡើង តាមដងផ្លូវដែល បើកឲ្យ ចរាចរជាសាធារណៈ ក្នុងអំឡុងពេលបណ្ណសន្យារ៉ាប់រងមានសុពលភាព ដែលបង្កឲ្យមានការស្លាប់ឬរបួសលើបុគ្គលម្នាក់ ឬច្រើននាក់។ គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវនេះ ត្រូវបង្កឡើងយ៉ាងហោចណាស់ដោយយានជំនិះដែលមានចលនាមួយ ហើយត្រូវរួមបញ្ចូលការប៉ះទង្គិចរវាងយានជំនិះ និងយានជំនិះ រវាងយានជំនិះ និង បុគ្គល និង រវាងយានជំនិះ និងសត្វពាហនៈ ឬវត្ថុណាមួយដែលជាឧបសគ្គ។

**១.៦. "គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយម៉ូតូ ម៉ូតូសណ្តោងរ៉ឺម៉ក ម៉ូតូកង់បី ឬ ម៉ូតូកង់បួន"** សំដៅលើឧបទ្ទវហេតុ ឬ គ្រោះថ្នាក់ចៃដន្យដែលកើតឡើងតាមដងផ្លូវដោយម៉ូតូ ម៉ូតូសណ្តោងរ៉ឺម៉ក ម៉ូតូកង់បី ឬ ម៉ូតូកង់បួនដោយ អ្នកត្រូវ បានធានារ៉ាប់រងត្រូវតែជាអ្នកបើកបរ ឬជាអ្នកដំណើរនៃម៉ូតូ ម៉ូតូសណ្តោងរ៉ឺម៉ក ម៉ូតូកង់បី ឬ ម៉ូតូកង់បួននោះផ្ទាល់។ ប្រការនេះ នឹងត្រូវពិចារណារួមគ្នាជាមួយនឹងប្រការ "**គ្រោះថ្នាក់ចៃដន្យ**" និង "**គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ**"។

**១.៧. "គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយរថយន្តគ្រួសារ រថយន្តទេសចរណ៍ ឬរថយន្តក្រុង"** សំដៅលើឧបទ្ទវហេតុ ឬគ្រោះថ្នាក់ចៃដន្យដែលកើតឡើងតាមដងផ្លូវដោយរថយន្តគ្រួសារ រថយន្តទេសចរណ៍ ឬរថយន្តក្រុង ដោយអ្នកត្រូវបានធានារ៉ាប់រងត្រូវតែជាអ្នកបើកបរ ឬជាអ្នកដំណើរនៃរថយន្តគ្រួសារ រថយន្តទេសចរណ៍ ឬ រថយន្តក្រុងនោះផ្ទាល់។ ប្រការនេះ នឹងត្រូវពិចារណារួមគ្នាជាមួយនឹងប្រការ "**គ្រោះថ្នាក់ចៃដន្យ**" និង "**គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ**"។

១.៨. **"ការបាត់បង់ដៃ/ជើងម្ខាង"** សំដៅដល់ការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងរហូត ឬការបាត់បង់ទាំងស្រុង/មិនអាចជាសះស្បើយជារៀងរហូតនៃមុខងារប្រើប្រាស់របស់ដៃម្ខាង ចាប់ពីផ្នែកខាងលើនៃកដៃ ឬរបស់ជើងម្ខាង ចាប់ពីផ្នែកខាងលើនៃកជើង។

ក្នុងករណីដែលមានការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងរហូតនៃមុខងារប្រើប្រាស់នៃដៃ ឬជើងម្ខាង ការវិភាគកោសល្យវិច្ច័យអំពីអាការៈនេះត្រូវធ្វើឡើងដោយមន្ទីរពេទ្យដែលមានចុះបញ្ជីត្រឹមត្រូវនៅថ្នាក់ខេត្ត ឬរាជធានី មិនឲ្យតិចជាងរយៈពេលប្រាំមួយ (៦) ខែ ហើយក៏មិនឲ្យលើសពីរយៈពេលប្រាំបួន (៩) ខែ គិតចាប់តាំងពីថ្ងៃដែលមានហេតុការណ៍ត្រូវបានធានាកើតឡើង ឬក៏គិតចាប់ពីថ្ងៃដែលការវិភាគកោសល្យវិច្ច័យអំពីអាការៈនេះត្រូវបានបញ្ជាក់ត្រឹមត្រូវដោយយកកាលបរិច្ឆេទចុងក្រោយ។

នៅក្នុងករណីដែលមានការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងរហូត ការវិភាគកោសល្យវិច្ច័យអំពីអាការៈនេះ អាចធ្វើឡើងនៅពេលណាមួយក៏បាន នៅតាមមន្ទីរពេទ្យដែលមានចុះបញ្ជីត្រឹមត្រូវនៅថ្នាក់ខេត្ត ឬរាជធានី។ ការវិភាគកោសល្យវិច្ច័យអំពីអាការៈនេះ អាចធ្វើឡើងនៅពេលណាមួយក៏បាននៅក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង និងនៅក្នុងរយៈពេលដែលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាពនៅឡើយ។

១.៩. **"ការបាក់ឆ្អឹង"** សំដៅដល់ការបាក់ទាំងស្រុងនៃឆ្អឹង។ ការបាក់នេះត្រូវមានភ្ជាប់មកជាមួយនូវការវិភាគកោសល្យវិច្ច័យដូចជា ការថតកាំរស្មីអិច (X-Ray) / ការថតស៊ីធីស្កេន (CT Scan) / ការថតអឹមរ៉ាយ (MRI)។ល។ លើកលែងតែ ក្នុង ករណី ការបាក់ នេះបានលេចឲ្យឃើញឆ្អឹងបាក់ជាក់ស្តែង។ ការបាក់ឆ្អឹងដែលមានស្នាមប្រេះស្ដើង (Hairline Fracture) និង ការបាក់ឆ្អឹង ដែលមិនបាក់ទាំងស្រុងដូចដើមឫស្សីបាក់ (Greenstick Fracture) មិនត្រូវបានរាប់បញ្ចូល នៅក្នុងអត្ថប្រយោជន៍នេះទេ។ ប្រភេទឆ្អឹងនៅក្នុងក្រុមឆ្អឹងនីមួយៗមានរៀបរាប់នៅក្នុងតារាងដូចខាងក្រោម៖

| ក្រុមឆ្អឹងប្រភេទទី ១ | ក្រុមឆ្អឹងប្រភេទទី ២ | ក្រុមឆ្អឹងប្រភេទទី ៣ |
|---|---|---|
| **ឆ្អឹងដងខ្លួន (Torso)** | **ឆ្អឹងអវយវៈលើ (Upper Extremity)** | **ឆ្អឹងលលាដ៍ក្បាល (Cranial bones)** |
| ឆ្អឹងជំនីរទី ១ ដល់ ១២ (Rib 1-12) | ឆ្អឹងដើមដៃ (Humerus) | ឆ្អឹងពយ (Occipital) |
| ឆ្អឹងសន្ទះទ្រូង (Sternum) | ឆ្អឹងតូចកំភួនដៃ (Radius) | ឆ្អឹងចំហៀង (Parietal) |
| **ឆ្អឹងអវយវៈលើ (Upper Extremity)** | ឆ្អឹងធំកំភួនដៃ (Ulna) | ឆ្អឹងថ្ងាស (Frontal) |
| ឆ្អឹងស្លាបប្រចៀវ (Scapula) | **ឆ្អឹងអវយវៈក្រោម (Lower Extremity)** | ឆ្អឹងសៀតផ្កា (Temporal) |
| ឆ្អឹងដងកាំបិត (Clavicle) | ឆ្អឹងភ្លៅ (Femur) | ឆ្អឹងស្វេណូអ៊ីត (Sphenoid) |
| ឆ្អឹងស្កាហ្វូអ៊ីត (Scaphoid) | ឆ្អឹងស្មង (Tibia) | ឆ្អឹងអេតម៉ូអ៊ីត (Ethmoid) |
| ឆ្អឹងសីមីលូនៃរ (Lunate) | ឆ្អឹងកំភួនជើង (Fibula) | **ឆ្អឹងមុខ (Facial bones)** |
| ឆ្អឹងពីរ៉ាមីដាល់ (Triquetrum) | | ឆ្អឹងច្រមុះ (Nasal) |
| ឆ្អឹងពីស៊ីហ្វម (Pisiform) | | ឆ្អឹងថ្គាមលើ (Maxillary) |
| ឆ្អឹងអូសក្រូស៊ី (Hamate) | | ឆ្អឹងរន្ធទឹកភ្នែក (Lacrimal) |
| ឆ្អឹងហ្គ្រង់អូស | | ឆ្អឹងថ្ពាល់ |

| |
|---|
| (Capitate) |
| ឆ្អឹងត្រាប៉េសូអ៊ីត (Trapezoid) |
| ឆ្អឹងត្រាប៉េ (Trapezium) |
| ឆ្អឹងប្រអប់ដៃទី ១ ដល់ ៥ (Metacarpal 1-5) |
| ឆ្អឹងម្រាមផ្នែកគល់ទី ១ ដល់ ៥ (Proximal Phalange 1-5) |
| ឆ្អឹងម្រាមផ្នែកកណ្ដាលទី ២ ដល់ ៥ (Middle Phalange 2-5) |
| ឆ្អឹងម្រាមផ្នែកចុងទី ១ ដល់ ៥ (Distal Phalange 1-5) |
| **ឆ្អឹងអវយវៈក្រោម (Lower Extremity)** |
| ឆ្អឹងអង្គញ់ (Patella) |
| ឆ្អឹងអាស្រ្តាហ្កាល់ (Talus) |
| ឆ្អឹងកាល់កានេអូម (Calcaneus) |
| ឆ្អឹងណាវីគុលលែរ (Navicular) |
| ឆ្អឹងគុយណេអ៊ីហ្វមខាងក្នុង (Medial Cuneiform) |
| ឆ្អឹងគុយណេអ៊ីហ្វមកណ្ដាល (Middle Cuneiform) |
| ឆ្អឹងគុយណេអ៊ីហ្វមខាងក្រៅ (Lateral Cuneiform) |
| ឆ្អឹងគុយបូអ៊ីត (Cuboid) |
| ឆ្អឹងប្រអប់ជើងទី ១ ដល់ ៥ (Metatarsal 1-5) |
| ឆ្អឹងម្រាមផ្នែកគល់ទី ១ ដល់ ៥ (Proximal Phalange 1-5) |
| ឆ្អឹងម្រាមផ្នែកកណ្ដាលទី ២ ដល់ ៥ (Middle Phalange 2-5) |
| ឆ្អឹងម្រាមផ្នែកចុងទី ១ ដល់ ៥ (Distal Phalange 1-5) |

| |
|---|
| (Zygomatic) |
| ឆ្អឹងក្រអូម (Palatine) |
| ឆ្អឹងប្រហោងច្រមុះ (Inferior Nasal Concha) |
| ឆ្អឹងសន្ទះច្រមុះ (Vomer) |
| ឆ្អឹងថ្គាមក្រោម (Mandible) |
| **ឆ្អឹងផ្សេងៗ (Associated Bones)** |
| ឆ្អឹងម៉ាតូ (Malleus) |
| ឆ្អឹងអង់ក្លូម (Incus) |
| ឆ្អឹងអេទ្រីយេ (Stapes) |
| ឆ្អឹងអ៊ីយ៉ូអ៊ីត (Hyoid) |
| **ឆ្អឹងដងខ្លួន (Torso)** |
| ឆ្អឹងកងកទី ១ ដល់ ៧ (Cervical Vertebrae: C1-7) |
| ឆ្អឹងកងខ្នងទី ១ ដល់ ១២ (Thoracic Vertebrae: T1-12) |
| ឆ្អឹងកងចង្កេះទី ១ ដល់ ៥ (Lumbar Vertebrae: L1-5) |
| ឆ្អឹងគូទ (Sacrum) |
| ឆ្អឹងកញ្ចុញគូទ (Coccyx) |
| **ឆ្អឹងអវយវៈក្រោម (Lower Extremity)** |
| ឆ្អឹងត្រគាក (Hip) |
| ឆ្អឹងត្រគាកផ្នែកខាងលើ (Ilium) |
| ឆ្អឹងត្រគាកផ្នែកខាងក្រោម (Ischium) |
| ឆ្អឹងថ្ងាស (Pubis) |

១.១០. **"ការវះកាត់"** គឺមានន័យថាជាបច្ចេកទេសក្នុងការព្យាបាលទៅលើជំងឺ ការរងរបួស និងការខូចទ្រង់ទ្រាយនៃ សរីរាង្គ ណាមួយរបស់សារពាង្គកាយ ដែលត្រូវបានអនុវត្តដោយគ្រូពេទ្យជំនាញ ឬគ្រូពេទ្យវះកាត់ដែលបានចុះបញ្ជីត្រឹមត្រូវ។ ការវះកាត់ រាប់បញ្ចូល ការកាត់ ការកោស ការដេរ ឬការផ្លាស់ប្តូរជាលិការាងកាយ និងសរីរាង្គ។

១.១១. **"មន្ទីរពេទ្យ"** សំដៅលើគ្រឹះស្ថានរដ្ឋ ឬឯកជនស្របច្បាប់ដែលបានចុះបញ្ជី និងត្រូវបានទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

- ប្រតិបត្តិការជាចម្បងសម្រាប់ការទទួលថែទាំ និងព្យាបាលជំងឺចំពោះអ្នកឈឺ និងរងរបួសដែលសម្រាកនៅមន្ទីរពេទ្យ
- ផ្តល់ជូនសេវាថែទាំ ២៤ ម៉ោងក្នុងមួយថ្ងៃ ដោយគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីត្រឹមត្រូវ
- មានបុគ្គលិកដែលជាគ្រូពេទ្យយ៉ាងតិចមួយនាក់ដែលប្រចាំការ
- មានគ្រឿងបរិក្ខារគ្រប់គ្រាន់ត្រឹមត្រូវ ដើម្បីធ្វើការវិភាគកោសល្យវិច្ឆ័យ និងការវះកាត់ធំៗ
- មិនមែនជាគ្លីនិក មណ្ឌលថែទាំ ឬគ្រឹះស្ថានប្រហាក់ប្រហែល ឬមណ្ឌលថែទាំចាស់ជរា អ្នកដែលមានបញ្ហាផ្លូវចិត្ត អ្នកញៀនស្រា ឬគ្រឿងញៀន និង
- មានបំពាក់ឧបករណ៍សម្រាប់ ការថតកាំរស្មីអ៊ិច (X-Ray) និងគ្រឿងបរិក្ខារសម្រាប់វះកាត់ជាដើម។

១.១២. **"ការសម្រាកនៅមន្ទីរពេទ្យ"** គឺជាអំឡុងពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្នាក់នៅមន្ទីរពេទ្យយ៉ាងតិចដប់ពីរ (១២) ម៉ោង តាមការណែនាំរបស់គ្រូពេទ្យ និងការបន្តស្នាក់នៅរហូតដល់អ្នកធានារ៉ាប់រងត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យ។ ការចូលមន្ទីរពេទ្យនេះត្រូវមានភ្ជាប់មកជាមួយនូវ ភស្តុតាងនៃការគិតថ្លៃបន្ទប់ស្នាក់នៅដោយមន្ទីរពេទ្យ ហើយក្រុមហ៊ុននឹងទូទាត់ អត្ថប្រយោជន៍ដោយគិតទៅតាមចំនួនថ្ងៃដែលស្នាក់នៅជាក់ស្តែង។

## ២. លក្ខខណ្ឌទាក់ទងនឹងបណ្ណសន្យារ៉ាប់រងរបស់អ្នក

សម្រាប់ការចេញបណ្ណសន្យារ៉ាប់រងនៃផលិតផលនេះ អ្នកត្រូវបានធានារ៉ាប់រងនឹងមិនតម្រូវឲ្យមានធ្វើការពិនិត្យសុខភាពឡើយ។ លក្ខខណ្ឌផ្សេងៗទាក់ទងនឹងផលិតផលនេះត្រូវបានរៀបរាប់ដូចខាងក្រោម៖

### ២.១. អត្ថប្រយោជន៍

អត្ថប្រយោជន៍ករណីគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ នឹងអាស្រ័យទៅលើប្រភេទអត្ថប្រយោជន៍ធានារ៉ាប់រងដែលបានជ្រើសរើស ដែលក្នុងនោះមាន (1). គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយម៉ូតូ ម៉ូតូសណ្តោងរ៉ឺម៉ក ម៉ូតូកង់បី ឬ ម៉ូតូកង់បួន; (2). គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយរថយន្តគ្រួសារ រថយន្តទេសចរណ៍ ឬរថយន្តក្រុង និង (3). គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវទូទៅ។

ប្រសិនបើគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយម៉ូតូ ម៉ូតូសណ្តោងរ៉ឺម៉ក ម៉ូតូកង់បី ឬ ម៉ូតូកង់បួនត្រូវបានជ្រើសរើស នោះអត្ថប្រយោជន៍ដូចរៀបរាប់ខាងក្រោម (ចំណុច ក ដល់ គ) នឹងត្រូវបានទូទាត់ នៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដែលមានពាក់ព័ន្ធនឹងអ្នកត្រូវបានធានារ៉ាប់រង ដែលជាអ្នកបើកបរ ឬ ជាអ្នកដំណើរនៃម៉ូតូ ម៉ូតូសណ្តោងរ៉ឺម៉ក ម៉ូតូកង់បី ឬ ម៉ូតូកង់បួននោះផ្ទាល់។

ប្រសិនបើគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវដោយរថយន្តគ្រួសារ រថយន្តទេសចរណ៍ ឬរថយន្តក្រុង ត្រូវបានជ្រើសរើស នោះអត្ថប្រយោជន៍ដូចរៀបរាប់ខាងក្រោម (ចំណុច ក ដល់ គ) នឹងត្រូវបានទូទាត់ នៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ ដែលមានពាក់ព័ន្ធនឹងអ្នកត្រូវបានធានារ៉ាប់រង ដែលជាអ្នកបើកបរ ឬ ជាអ្នកដំណើរនៃរថយន្តគ្រួសារ រថយន្តទេសចរណ៍ ឬរថយន្តក្រុងនោះផ្ទាល់។

ប្រសិនបើគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវទូទៅ ត្រូវបានជ្រើសរើស នោះអត្ថប្រយោជន៍ដូចរៀបរាប់ខាងក្រោម (ចំណុច ក ដល់ គ) នឹងត្រូវបានទូទាត់ នៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ។

ក. **អត្ថប្រយោជន៍ករណីបាត់បង់ដៃ/ជើងម្ខាង៖** ១០០% នៃអត្ថប្រយោជន៍ក្នុងករណីបាត់បង់ដៃ/ជើងម្ខាង នឹងត្រូវផ្តល់ជូនទៅកាន់ករណីអ្នកត្រូវបានធានារ៉ាប់រងបាត់បង់ដៃ/ជើងម្ខាង ប្រសិនបើអត្ថប្រយោជន៍ករណីបាត់បង់ដៃ/ជើងម្ខាងត្រូវបានជ្រើសរើស។

ខ. **អត្ថប្រយោជន៍ករណីបាក់ឆ្អឹង៖** ករណីអ្នកត្រូវបានធានារ៉ាប់រងទទួលរងការបាក់ឆ្អឹង ហើយប្រសិនបើអត្ថប្រយោជន៍ករណីបាក់ឆ្អឹងត្រូវបានជ្រើសរើស នោះ ១០០% នៃអត្ថប្រយោជន៍ក្នុងករណីបាក់ឆ្អឹងនឹងត្រូវបានទូទាត់ស្របទៅតាមប្រភេទនៃការបាក់ឆ្អឹងដូចខាងក្រោម៖

- ការបាក់ឆ្អឹងក្នុងក្រុមឆ្អឹងប្រភេទទី **១** ទទួលបាន ២០ ដុល្លារអាមេរិក
- ការបាក់ឆ្អឹងក្នុងក្រុមឆ្អឹងប្រភេទទី **២** ទទួលបាន ៣០ ដុល្លារអាមេរិក
- ការបាក់ឆ្អឹងក្នុងក្រុមឆ្អឹងប្រភេទទី **៣** ទទួលបាន ៥០ ដុល្លារអាមេរិក
- អត្ថប្រយោជន៍បន្ថែមលើការវះកាត់ ទទួលបាន ១០០ ដុល្លារអាមេរិក (ប្រសិនការវះកាត់ គឺជាតម្រូវការចាំបាច់ពីគ្រូពេទ្យឯកទេសវះកាត់ជំងឺឆ្អឹង)។

គ. **អត្ថប្រយោជន៍សម្រាប់ការព្យាបាលនៅមន្ទីរពេទ្យ៖** ១០០% នៃអត្ថប្រយោជន៍សម្រាប់ការព្យាបាលនៅមន្ទីរពេទ្យនឹងត្រូវបានផ្តល់ជូន ករណីអ្នកត្រូវបានធានារ៉ាប់រងត្រូវសម្រាកនៅមន្ទីរពេទ្យ ប្រសិនបើអត្ថប្រយោជន៍សម្រាប់ការព្យាបាលនៅមន្ទីរពេទ្យត្រូវបានជ្រើសរើស។

**អត្ថប្រយោជន៍ដែលបានរៀបរាប់ខាងលើនឹងត្រូវបានផ្តល់ជូនស្របទៅតាមលក្ខខណ្ឌដូចខាងក្រោម៖**

- អត្ថប្រយោជន៍ករណីបាត់បង់ដៃ/ជើងម្ខាងនឹងត្រូវបានទូទាត់តែម្តងប៉ុណ្ណោះ ចំពោះអ្នកត្រូវបានធានារ៉ាប់រងម្នាក់ក្នុងអំឡុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង។
- អត្ថប្រយោជន៍ក្នុងករណីបាក់ឆ្អឹង នឹងត្រូវបានទូទាត់តែម្តងប៉ុណ្ណោះ ចំពោះអ្នកត្រូវបានធានារ៉ាប់រងម្នាក់ ក្នុងអំឡុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង និងការទូទាត់អត្ថប្រយោជន៍មានតម្លៃជាអតិបរមាត្រឹម ២០០ ដុល្លារអាមេរិកប៉ុណ្ណោះ សម្រាប់អ្នកត្រូវបានធានារ៉ាប់រងម្នាក់។
- អត្ថប្រយោជន៍សម្រាប់ការព្យាបាលនៅមន្ទីរពេទ្យអាចត្រូវបានទូទាត់លើសពី ១ ដង ក្នុងអំឡុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង។ អត្ថប្រយោជន៍សម្រាប់ការព្យាបាលនៅមន្ទីរពេទ្យ គឺកំណត់ត្រឹម ១០ ថ្ងៃ ក្នុងមួយករណីគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ ឬកំណត់ត្រឹម ៣០ ថ្ងៃសម្រាប់រយៈពេលកំណត់មួយឆ្នាំនៃបណ្ណសន្យារ៉ាប់រង។ អត្ថប្រយោជន៍សម្រាប់ការព្យាបាលនៅមន្ទីរពេទ្យសម្រាប់ការព្យាបាលនៅមន្ទីរពេទ្យបន្ទាប់ពីរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង នឹងត្រូវទូទាត់លុះត្រាតែកាលបរិច្ឆេទចាប់ផ្តើមការសម្រាលព្យាបាលនៅមន្ទីរពេទ្យស្ថិតក្នុងអំឡុងរយៈពេលកំណត់មួយឆ្នាំនៃបណ្ណសន្យារ៉ាប់រង។

ផលិតផលធានារ៉ាប់រងបន្ថែមនឹងត្រូវបញ្ចប់បន្ទាប់ពីការទូទាត់ខាងលើ ចំពោះអ្នកត្រូវបានធានារ៉ាប់រងម្នាក់ ហើយពុំមានអត្ថប្រយោជន៍នឹងត្រូវទូទាត់បន្តទៀតទេ។

### ២.២. ករណីមិនត្រូវបានធានា

ក្រុមហ៊ុននឹងបដិសេធក្នុងការទូទាត់អត្ថប្រយោជន៍ដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើការទាមទារសំណងរបស់អ្នកត្រូវបានធានារ៉ាប់រងត្រូវបានកើតឡើងដូចលក្ខខណ្ឌខាងក្រោម៖

ក. ការធ្វើអត្តឃាត ឬ ការប៉ុនប៉ងធ្វើអត្តឃាត ឬ ធ្វើឲ្យរបួសខ្លួនឯង ឬ ការដែលមិនបានប្រើប្រាស់សមត្ថភាពឲ្យសមហេតុផលដើម្បីជៀសវាងពីការរងរបួស ទោះបីជាអ្នកត្រូវបានធានារ៉ាប់រង ស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬ មិនប្រក្រតីក៏ដោយ។

ខ. ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីបទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្ត ដោយអ្នកទទួលផលម្នាក់ ឬច្រើននាក់ អ្នកត្រូវបានធានារ៉ាប់រង ម្ចាស់បណ្ណសន្យារ៉ាប់រង និង អត្តគាហក នោះមានតែអ្នកទទួលផល នោះមានតែអ្នកទទួលផល អ្នកត្រូវបានធានារ៉ាប់រង ម្ចាស់បណ្ណសន្យារ៉ាប់រង ឬ អត្តគាហក ដែលមិនពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌប៉ុណ្ណោះ ដែលនៅមានសិទ្ធិក្នុងការទទួលអត្ថប្រយោជន៍។

គ. ការប្រើគ្រឿងញៀន ឬថ្នាំសប្បាយ ការទទួលរងគ្រោះដោយការគេចវេស ឬទប់ទល់នឹងការចាប់ខ្លួនរបស់មន្ត្រីអនុវត្តច្បាប់ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬ/និង ការបើកបរហួសល្បឿនកំណត់ ឬ ការបើកបរយានជំនិះនៅអាយុដែលមិនបានអនុញ្ញាតដោយច្បាប់ ឬ មិនមានបណ្ណបើកបរត្រឹមត្រូវ ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន

ឃ. ការចូលរួមនៅក្នុងសកម្មភាពប្រណាំងបើកបរ

ង. មានជំងឺផ្លូវចិត្ត ជំងឺថប់បារម្ភ ឬជំងឺប្រព័ន្ធសរសៃប្រសាទ

ច. បញ្ហារាងកាយដែលមានស្រាប់មុនពេលកាលបរិច្ឆេទចាប់ផ្តើមសុពលភាពការធានារ៉ាប់រង

## ២.៣. ការទាមទារសំណង

ការទាមទារសំណងលើហេតុការណ៍ដែលត្រូវបានធានា ត្រូវតែធ្វើឡើង និងត្រូវដាក់សំណើសុំមកកាន់ក្រុមហ៊ុនក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីការកើតឡើងនៃឧបទ្ទវហេតុ។ ក្រុមហ៊ុននឹងទូទាត់ប្រាក់អត្ថប្រយោជន៍ស្របតាម ខ និងលក្ខខណ្ឌនេះ លុះត្រាណាតែក្រុមហ៊ុនទទួលបានភស្តុតាងដែលចាំបាច់ និងអាចទុកចិត្តបានសម្រាប់ការទូទាត់សំណង។ ឯកសារខាងក្រោមនេះ ចាំបាច់ត្រូវមានសម្រាប់ការវាយតម្លៃទៅលើការទាមទារសំណង៖

ក. ទម្រង់បែបបទទាមទារសំណង
ខ. របាយការណ៍ប៉ូលីសទាក់ទងនឹងគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ
គ. របាយការណ៍វេជ្ជសាស្ត្រ រួមបញ្ចូលទាំង របាយការណ៍ពិនិត្យជាតិអាកុល ឬសារធាតុញៀន ដើម្បី សន្មតថាគ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវមិនបណ្តាលមកពីការបើកបរដោយមានជាតិស្រវឹង ឬគ្រឿងញៀន
ឃ. ភស្តុតាងពីកាសែត ឬទស្សនាវដ្តី ដែលបង្ហាញពីហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍តាមដងផ្លូវ (ប្រសិនបើមាន)។

បន្ថែមលើឯកសារខាងលើ ឯកសារផ្សេងទៀតដែលចាំបាច់ត្រូវមានសម្រាប់ការវាយតម្លៃទៅលើការទាមទារសំណងមានដូចជា៖

ក. **ករណីបាត់បង់ដៃ/ជើងម្ខាង៖** ការទាមទារសំណងត្រូវភ្ជាប់មកជាមួយនឹងលិខិតបញ្ជាក់ពីការបាត់បង់ដៃ/ជើងម្ខាង ដោយគ្រូពេទ្យជំនាញពីគ្លីនិក ឬមន្ទីរពេទ្យដែលមានចុះបញ្ជី។
ខ. **ករណីនៃការសម្រាកនៅមន្ទីរពេទ្យ៖** ការទាមទារសំណង ត្រូវភ្ជាប់មកជាមួយនឹង លិខិតបញ្ជាក់ ពី ការចាកចេញ ពីមន្ទីរពេទ្យ។
គ. **ករណីបាក់ឆ្អឹង៖** ការទាមទារសំណងត្រូវភ្ជាប់មកជាមួយនឹងឯកសារនៃការថតកាំរស្មីអិច (X-Ray) / ការថតអឹមរ៉ាយ (MRI) / ការថតស៊ីធីស្កេន (CT Scan) និងលិខិតបញ្ជាក់ពីការចាកចេញពីមន្ទីរពេទ្យ រួមទាំងលិខិតប្រកាស ពីការវះកាត់ដោយគ្រូពេទ្យឯកទេសវះកាត់ជំងឺឆ្អឹងនៃមន្ទីរពេទ្យ ឬគ្លីនិកដែលបានចុះបញ្ជី ប្រសិនបើការវះកាត់តម្រូវឲ្យមាន។

## ២.៤. ការដោះស្រាយវិវាទ

ចំពោះគ្រប់វិវាទដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ។

